**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៦៩៤ ព.ណ.នន...

ថ្ងៃព្រហស្បតិ៍ ១២កើត ខែចេត្រ ឆ្នាំឆ្លូវត្រីស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ **អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់** ឱ្យបានជ្រាបថា រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានឯកភាព និងបានបញ្ចប់នីតិវិធីផ្ទៃក្នុង សម្រាប់បន្តសុពលភាពនៃ **«កិច្ចសម្របសម្រួលជំរុញពាណិជ្ជកម្មទ្វេភាគី រវាង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ឆ្នាំ ២០១៩-២០២០»** សម្រាប់បន្តអនុវត្តនៅ ឆ្នាំ២០២១-២០២២។ **ព្រះរាជាណាចក្រកម្ពុជា** ទទួលបានភាពអនុគ្រោះពន្ធសូន្យភាគរយ ចំពោះមុខទំនិញចំនួន ៣១ បន្ទាត់ពន្ធគយ ដែលមានដើមកំណើតនៅព្រះរាជាណាចក្រកម្ពុជា នាំចេញទៅសាធារណរដ្ឋសង្គមនិយមវៀតណាម (ដូចមានក្នុងឧបសម្ព័ន្ធ)។

ផលិតករ ឬអ្នកនាំចេញ អាចធ្វើការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេស (CO Form S) តាមរយៈគេហទំព័រ https://co.moc.gov.kh/ ចំពោះមុខទំនិញក្នុងឧបសម្ព័ន្ធ។ ដោយឡែកសម្រាប់បរិមាណមុខទំនិញ អង្ករ និងសន្លឹកថ្នាំជក់ស្ងួត សម្រាប់អនុវត្តឆ្នាំ២០២១ សូមផលិតករ ឬអ្នកនាំចេញ ដាក់ពាក្យស្នើសុំមកក្រសួងពាណិជ្ជកម្ម (នាយកដ្ឋាននាំចេញ-នាំចូល នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម) រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់** មេត្តាជ្រាបជាព័ត៌មាន។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469